មេរៀនទី១២

# មានការគោរពចំពោះជីវិតនិងឈាម

*តើយើងគួរមានទស្សនៈយ៉ាងណាអំពីជីវិត? (១) អំពីការពន្លូតកូន? (១)*

*តើតាមរបៀបណាដែលគ្រីស្ទានបង្ហាញថាគេមានសម្បជញ្ញៈអំពីការជៀសវាងពីគ្រោះថ្នាក់? (២)*

*តើការសម្លាប់សត្វគឺជាការខុសឬ? (៣)*

*តើអ្វីខ្លះជាការប្រព្រឹត្តដែលមិនសម្តែងនូវការគោរពចំពោះជីវិត? (៤)*

*តើអ្វីជាច្បាប់របស់ព្រះអំពីឈាម? (៥)*

*តើនេះមានរួមការបញ្ចូលឈាមឬទេ? (៦)*

១. ព្រះយេហូវ៉ាគឺជាប្រភពនៃជីវិត ។ របស់រស់នៅទាំងឡាយមានជីវិតគឺដោយសារព្រះ ។ (ទំនុកដំកើង ៣៦:៩) ជីវិតគឺពិសិដ្ឋណាស់ចំពោះព្រះ ។ សូម្បីជីវិតនៃទារកក្នុងផ្ទៃម្ដាយក៏មានតម្លៃចំពោះព្រះយេហូវ៉ាដែរ ។ សម្លាប់ទារកដែលកំពុងលូតលាស់ក្នុងផ្ទៃបែបនេះដោយបំណង នោះគឺខុសហើយចំពោះព្រះនេត្រនៃព្រះ ។—និក្ខមនំ ២១:២២, ២៣; ទំនុកដំកើង ១២៧:៣

២. គ្រីស្ទានពិតគឺមានសម្បជញ្ញៈអំពីការជៀសវាងពីគ្រោះថ្នាក់ ។ ពួកគេយកចិត្តទុកដាក់ប្រយ័ត្នដល់រថយន្តនិងផ្ទះរបស់គេ ដើម្បីកុំឲ្យគ្រោះថ្នាក់កើតឡើង ។ (ចោទិយកថា ២២:៨) អ្នកបំរើព្រះមិនយកជីវិតរបស់ខ្លួនមកប្រថុយលេងៗ ដើម្បីជាការកំសាន្តសប្បាយឬការរំភើបចិត្តប៉ុណ្ណោះឡើយ ។ ដូច្នេះ ពួកគេមិនចូលរួមក្នុងកីឡាឃោរឃៅណាដែលនាំឲ្យមានការឈឺចាប់ដល់មនុស្សឯទៀតដោយចេតនាទេ ។ ពួកគេជៀសវាងការកំសាន្តដែលជំរុញទឹកចិត្តឲ្យប្រព្រឹត្ត

អំពើឃោរឃៅ ។—ទំនុកដំកើង ១១:៥; យ៉ូហាន ១៣:៣៥

៣. ជីវិតនៃសត្វក៏ពិសិដ្ឋចំពោះព្រះអាទិទេពដែរ ។ គ្រីស្ទានអាចសម្លាប់សត្វបាន ដើម្បីផ្ដល់ជាចំណីអាហារ និងសំលៀកបំពាក់ ឬដើម្បីការពារខ្លួនពីរោគជម្ងឺនិងគ្រោះថ្នាក់ ។ (លោកុប្បត្តិ ៣:២១; ៩:៣; និក្ខមនំ ២១:២៨) ប៉ុន្តែធ្វើបាបសត្វឬក៏សម្លាប់សត្វលេងទុកដូចជាកីឡា ឬកំសាន្តសប្បាយ នោះគឺមិនត្រូវទេ ។—សុភាសិត ១២:១០

៤. ការជក់បារី ទំពាស្លា និងប្រើថ្នាំដើម្បីកំសាន្តសប្បាយ គឺមិនមែនសំរាប់គ្រីស្ទានឡើយ ។ ការប្រព្រឹត្តទាំងនេះគឺខុស ពីព្រោះ (១) វាធ្វើឲ្យយើងញៀន (២) វាធ្វើទុក្ខដល់រូបកាយរបស់យើង ហើយ (៣) វាមិនមែនជាការស្អាតស្អំទេ ។ (រ៉ូម ៦:១៩; ១២:១; កូរិនថូសទី២ ៧:១) ការលះបង់ទម្លាប់ទាំងនេះចោល គឺជាការពិបាកណាស់ ។ ប៉ុន្តែ យើងត្រូវតែលះបង់ចោលទើបយើងផ្គាប់ព្រះហឫទ័យនៃព្រះយេហូវ៉ាបាន ។

៥. ឈាមក៏ជារបស់ពិសិដ្ឋដែរចំពោះព្រះនេត្រនៃព្រះ ។ ព្រះមានបន្ទូលថា ព្រលឹងឬជីវិតគឺនៅក្នុងឈាម ។ ដូច្នេះ ការបរិភោគឈាមគឺជាការខុស ។ ហើយការបរិភោគសាច់នៃសត្វដែលគេមិនបានបង្ហូរឈាមចោលឲ្យអស់ក៏ជាការខុសដែរ ។ បើសត្វណាដែលគេគាបច្របាច់កឬស្លាប់ដោយអន្ទាក់ សត្វនោះយើងមិនគួរបរិភោគទេ ។ បើសត្វនោះត្រូវគេចាក់ឬត្រូវគេបាញ់ នោះត្រូវតែបង្ហូរឈាមវាចោលជាប្រញាប់ បើសិនយើងចង់បរិភោគសាច់វា ។—លោកុប្បត្តិ ៩:៣, ៤; លេវីវិន័យ ១៧:១៣, ១៤; កិច្ចការ ១៥:២៨, ២៩

៦. តើទទួលការបញ្ចូលឈាមគឺជាការខុសឬទេ ? សូមចាំថា ព្រះយេហូវ៉ាទ្រង់តម្រូវឲ្យយើងជៀសវាងពីឈាម ។ នេះមានន័យថាយើងមិនត្រូវយកឈាមរបស់មនុស្សឯទៀតឬសូម្បីឈាមរបស់ខ្លួនយើងដែលបានសន្សំទុក មកបញ្ចូលក្នុងរូបកាយយើងតាមវិធីណាឡើយ ។ (កិច្ចការ ២១:២៥) ដូច្នេះ គ្រីស្ទានពិតមិនទទួលការបញ្ចូលឈាមទេ ។ ពួកគេនឹងទទួលវិធីព្យាបាលពេទ្យផ្សេងៗឯទៀត ដូចជាការបញ្ចូលធាតុដែលមិនមានជាតិឈាមជាដើម ។ ពួកគេចង់មានជីវិតរស់នៅ ប៉ុន្តែពួកគេនឹងមិនខំរកសង្គ្រោះជីវិតខ្លួនដោយបំពានលើច្បាប់របស់ព្រះឡើយ ។—ម៉ាថាយ ១៦:២៥



*ដើម្បីផ្គាប់ព្រះហឫទ័យនៃព្រះ យើងត្រូវតែជៀសវាងការបញ្ចូលឈាម ជៀសវាងទម្លាប់មិនស្អាតស្អំ និងការប្រថុយដ៏មិនចាំបាច់ ដែលអាចនាំឲ្យមានគ្រោះថ្នាក់*



